ព្រះរាជក្រឹត្យ

នស/រកត/០៧១៩/ ១០៤៤

ស្តីពី

ការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រសួងមុខងារសាធារណៈ
រដ្ឋបាល
ចូល
លេខ: ៤៦៦២
មកដល់ថ្ងៃទី១៥ ខែ០៧ ឆ្នាំ១៩
ម៉ោង ១០:២២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើត **គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** សរសេរជាអក្សរកាត់ថា **"គ.ស.ហ."** ដើម្បីធានាស្ថិរភាពហិរញ្ញវត្ថុ ជំរុញកំណើននិងពង្រឹងភាពធន់សេដ្ឋកិច្ច និងលើកកម្ពស់ការអភិវឌ្ឍប្រកបដោយសមធម៌ និងបរិយាប័ន្ន ។

ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

មាត្រា២.-

គ.ស.ហ. មានភារកិច្ចដូចតទៅ÷

- ដឹកនាំ, រៀបចំ, សម្របសម្រួល, តាមដាន, ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តគោលនយោបាយ និងកិច្ចការកែទម្រង់ក្នុងវិស័យសង្គម-សេដ្ឋកិច្ច និងហិរញ្ញវត្ថុ របស់រាជរដ្ឋាភិបាល
- សម្របសម្រួល, តាមដាន, ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ ស្តីពីការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ
- ដឹកនាំ, រៀបចំ, សម្របសម្រួល, តាមដាន, ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍវិស័យឯកជន និងការកែលម្អភាពប្រកួតប្រជែងរបស់កម្ពុជា
- ដឹកនាំ, សម្របសម្រួល និងដោះស្រាយការងារ និងបញ្ហាផ្សេងៗដែលមានលក្ខណៈអន្តរស្ថាប័ន ពាក់ព័ន្ធនឹងវិស័យសង្គម-សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំសូចនាករសមិទ្ធផលគន្លឹះ និងដឹកនាំការងារត្រួតពិនិត្យ, តាមដាន និង វាយតម្លៃការអនុវត្តយុទ្ធសាស្ត្រចតុកោណ និង យុទ្ធសាស្ត្រថ្មីបន្តបន្ទាប់ទៀត ទៅតាមនីតិកាលនីមួយៗរបស់រាជរដ្ឋាភិបាល
- សម្របសម្រួលក្នុងកម្រិតគោលនយោបាយនូវកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍លើការងារកែទម្រង់ក្នុងវិស័យសង្គម-សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ របស់រាជរដ្ឋាភិបាល ។

## ជំពូកទី២

## សមាសភាពនិងរចនាសម្ព័ន្ធ

មាត្រា៣.-

គ.ស.ហ. មានសមាសភាព ដូចតទៅ÷

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២- ទេសាភិបាលធនាគារជាតិនៃកម្ពុជា | អនុប្រធាន |
| ៣- រដ្ឋមន្ត្រីក្រសួងផែនការ | អនុប្រធាន |
| ៤- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ៥- រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៦- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៧- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៨- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៩- រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| ១០- រដ្ឋមន្ត្រីក្រសួងសុខាភិបាល | សមាជិក |
| ១១- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| ១២- រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

១៣- រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល សមាជិក
១៤- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
១៥- រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក
១៦- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម សមាជិក
១៧- រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សមាជិក
១៨- រដ្ឋមន្ត្រីក្រសួងបរិស្ថាន សមាជិក
១៩. រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
២០- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
២១- តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ សមាជិក
២២- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

គ.ស.ហ. អាចមានសមាសភាពបន្ថែម ជារដ្ឋមន្ត្រី, ប្រធានស្ថាប័ន, ឬ តំណាងនៃក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀតនៃរាជរដ្ឋាភិបាល តាមការចាំបាច់ ។

សមាសភាពជាក់ស្តែងនៃ គ.ស.ហ. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

**មាត្រា៤.-**

គ.ស.ហ. អាចមានគណៈកម្មាធិការ, អនុគណៈកម្មាធិការ, ឬ ក្រុមការងារផ្សេងៗ ដើម្បីបម្រើការងារក្នុងការបំពេញភារកិច្ចដូចមានចែងក្នុងមាត្រា២ ខាងលើ តាមតម្រូវការចាំបាច់ ។ គណៈកម្មាធិការ, អនុគណៈកម្មាធិការ ឬ ក្រុមការងាររបស់ គ.ស.ហ. ត្រូវបង្កើតឡើងដោយអនុក្រឹត្យ ឬ សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់ប្រធាន គ.ស.ហ.។

## ជំពូកទី៣
## ការប្រព្រឹត្តិទៅនៃ គ.ស.ហ.

**មាត្រា៥.-**

តាមការអញ្ជើញរបស់ប្រធាន, សមាជិក និង អនុប្រធាន គ.ស.ហ. ត្រូវចូលរួមប្រជុំ ឬ ចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចជំនួស ដើម្បីចូលរួមប្រជុំ ក្នុងករណីអវត្តមាន ឬ មានធុរៈ។

គ.ស.ហ. ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ដំណើរការការងារ ។

**មាត្រា៦.-**

ប្រធាន គ.ស.ហ. មានសិទ្ធិអញ្ជើញប្រធានស្ថាប័ន ឬ តំណាងរបស់ប្រធានស្ថាប័ន ឬ អាជ្ញាធរ ព្រមទាំងមន្ត្រីបច្ចេកទេសនៃក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ចូលរួមប្រជុំ និង បំពេញការងារ ស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងអនុក្រឹត្យនេះ ។

ROYAUME DU CAMBODGE · MINISTÈRE DU PALAIS ROYAL

មាត្រា៧.-

គ.ស.ហ. ព្រមទាំងគណៈកម្មាធិការ, អនុគណៈកម្មាធិការ និង ក្រុមការងារបច្ចេកទេស មានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន តំណាងសង្គមស៊ីវិល ទីប្រឹក្សា ឬអ្នកជំនាញការជាតិ និងអន្តរជាតិ ចូលរួមប្រជុំ ក្នុងឋានៈជាសមាជិក អ្នកសង្កេតការណ៍ ឬ អ្នកផ្តល់យោបល់ តាមការចាំបាច់ ។

មាត្រា៨.-

គ.ស.ហ. មានអគ្គលេខាធិការដ្ឋានមួយ ជាសេនាធិការសម្រាប់បំពេញមុខងាររបស់ខ្លួន ។ អគ្គលេខាធិការដ្ឋានដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងពីររូប និង ទីប្រឹក្សាមួយរូប ព្រមទាំងអ្នកស្រាវជ្រាវ ជំនួយការអ្នកស្រាវជ្រាវ និង មន្ត្រីមួយចំនួនតាមការចាំបាច់ ។

អគ្គលេខាធិការ, អគ្គលេខាធិការរង និងទីប្រឹក្សា ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

អ្នកស្រាវជ្រាវ, ជំនួយការអ្នកស្រាវជ្រាវ និងមន្ត្រី នៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. ត្រូវតែងតាំងដោយអនុក្រឹត្យ ឬ ប្រកាស អនុលោមតាមបទប្បញ្ញត្តិជាធរមាន ។

មាត្រា៩.-

ប្រភពធនធានសម្រាប់ទ្រទ្រង់អគ្គលេខាធិការដ្ឋាននៃ គ.ស.ហ. រួមមាន ប្រភពថវិកាជាតិ, ថវិកាដៃគូ និង ប្រភពស្របច្បាប់ផ្សេងទៀត ។

មាត្រា១០.-

ក្នុងការបំពេញមុខងាររបស់ខ្លួនជាសេនាធិការបច្ចេកទេសរបស់ គ.ស.ហ., អគ្គលេខាធិការដ្ឋាន គ.ស.ហ. មានភារកិច្ច ដូចតទៅ÷

- រៀបចំតាមដាន និង វាយតម្លៃការអនុវត្តគោលនយោបាយ និងកិច្ចការកែទម្រង់ក្នុងវិស័យសង្គម-សេដ្ឋកិច្ច និងហិរញ្ញវត្ថុ របស់រាជរដ្ឋាភិបាល
- សហការ និងសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន និងអង្គភាពនានារបស់រាជរដ្ឋាភិបាល, ដៃគូអភិវឌ្ឍន៍ និងគូអង្គពាក់ព័ន្ធនានា ដើម្បីតាមដាន, ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងកិច្ចការកែ-ទម្រង់ក្នុងវិស័យសង្គម-សេដ្ឋកិច្ច និងហិរញ្ញវត្ថុ របស់រាជរដ្ឋាភិបាល
- រៀបចំធ្វើកិច្ចការស្រាវជ្រាវ ព្រមទាំងការសម្របសម្រួល និងការរៀបចំកិច្ចពិគ្រោះយោបល់នានា ទាំងក្នុងចំណោមស្ថាប័នជាតិ និង ជាមួយដៃគូអន្តរជាតិ អំពីគោលនយោបាយ និងកិច្ចការកែទម្រង់ក្នុងវិស័យសង្គម-សេដ្ឋកិច្ច និងហិរញ្ញវត្ថុ របស់រាជរដ្ឋាភិបាល
- រៀបចំកិច្ចប្រជុំរបស់ គ.ស.ហ. តាមការណែនាំរបស់ប្រធាន គ.ស.ហ.
- រៀបចំកំណត់ហេតុអង្គប្រជុំ និង ធ្វើសេចក្តីជូនដំណឹងស្តីពីការសម្រេចរបស់ គ.ស.ហ. និងសេចក្តីជូនដំណឹងស្តីពីការសម្រេចរបស់រាជរដ្ឋាភិបាល លើសំណើ និងអនុសាសន៍នានារបស់ គ.ស.ហ. ដល់សមាជិក គ.ស.ហ. និងអង្គភាពពាក់ព័ន្ធក្រោមឱវាទ គ.ស.ហ.
- សម្របសម្រួលការងារប្រចាំថ្ងៃរបស់ គ.ស.ហ. ស្របតាមការណែនាំ និងការសម្រេចរបស់ប្រធាន គ.ស.ហ. និង
- បំពេញភារកិច្ចផ្សេងទៀត តាមការណែនាំរបស់ប្រធាន គ.ស.ហ. ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ជំពូកទី៤

អវសានប្បញ្ញត្តិ

**មាត្រា១១.-**

លិខិតបទដ្ឋានគតិយុត្តជាធរមាន ដែលត្រូវបានដាក់ឱ្យអនុវត្ត ដោយអនុលោមតាមព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបន្តអានុភាពអនុវត្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មី មកជំនួស ។

ព្រះរាជក្រឹត្យនេះ ត្រូវជំនួស ព្រះរាជក្រឹត្យ ដូចខាងក្រោម÷

- ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៩៣ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា២ មាត្រា៣ មាត្រា៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១២.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១៩

រកត. ១៧០៧. ៧០២៩

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**